ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

តុលាការរដ្ឋប្បវេណី

**សំណុំរឿងរដ្ឋប្បវេណីលេខ ៥៨៨**

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣

**សាលក្រមរដ្ឋប្បវេណីលេខ ៥៤ ប**

ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ៖ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមជំនុំជម្រះ

**ក្រឡាបញ្ជី**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ក. អំពីអត្តសញ្ញាណភាគី**

ដើមចោទដែលជា [redacted] តំណាងដោយឈ្មោះ [redacted] ជាប្រធាននាយកប្រតិបត្តិ។

អាសយដ្ឋាន [redacted]

**អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ [redacted]

សហចុងចម្លើយឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

សហចុងចម្លើយឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៨២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

សហចុងចម្លើយឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៨១ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

សហចុងចម្លើយឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៩ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

សហចុងចម្លើយឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៥១ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

សហចុងចម្លើយឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៤៩ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

អាសយដ្ឋាន [redacted]



Scanned with CamScanner

## អង្គហេតុ និងចំណុចវិវាទ

### ក. ខ្លឹមសារនៃពាក្យបណ្ដឹងដែលដើមចោទទាមទារឱ្យតុលាការចេញ

១. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក។

២. អំពីការប្រាក់៖ បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងការប្រាក់មកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួនក្នុងអត្រាការប្រាក់ ១.៣៥ % ក្នុងមួយខែ លើប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២២។

៣. អំពីសំណងការខូចខាត៖ បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងការប្រាក់ពិន័យមកដើមចោទគិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រា ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២។

៤. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ ផូ ភីន ឈ្មោះ [redacted] គី ឈ្មោះ ផន ផូ រួមគ្នាសងថ្លៃសេវាកម្មច្បាប់ និងការខាតបង់ពេលវេលាមកដើមចោទចំនួន ១០.០០០.០០០ (ដប់លាន) រៀល។

៥. ប្រាក់ប្រដាប់ក្ដី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់សហចុងចម្លើយ។

៦. ស្នើសុំអនុវត្តបណ្ដោះអាសន្ន បានត្រង់ចំណុច (១,២,៣) នៃចំណុចទាមទារខាងលើ។

### ខ. ដំណើររឿងក្ដី និងចំណុចវិវាទ

#### ខ.១. ការសង្ខេបអំពីរឿងក្ដី

តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ រវាងដើមចោទ និងសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ដែលបានព្រមព្រៀងក្នុងការខ្ចីប្រាក់ពីដើមចោទសរុប ១២,២០០ (មួយម៉ឺនពីរពាន់ពីររយ) ដុល្លារអាមេរិក ក្នុងរយៈពេល ៩៦ (កៅសិបប្រាំមួយ) ខែ អត្រាការប្រាក់ ១,៣៥ (មួយចុចសាមសិបប្រាំ) ភាគរយក្នុងមួយខែ។ ក្រោយពីទទួលប្រាក់ពីដើមចោទ សហចុងចម្លើយបានបង់ប្រាក់ដើមបូកនឹងការប្រាក់តាមតារាងបង់ប្រាក់រៀងរាល់ខែ រហូតដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ សហចុងចម្លើយបានខកខានសងប្រាក់ដើម និងការប្រាក់ រហូតមកដល់បច្ចុប្បន្ន សរុបជាទឹក



Scanned with CamScanner

ប្រាក់ចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក ដែលជាហេតុធ្វើឱ្យមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ដើមចោទ។

**ខ.២. អង្គហេតុដែលគ្មានវិវាទ៖ គ្មាន។**

**ខ.៣. អំពីចំណុចវិវាទ**

**ខ.៣.១. ស្តីពីចំណុចវិវាទទី១៖** តើការទាមទាររបស់ដើមចោទឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ ជាការត្រឹមត្រូវដែរឬទេ?

**ខ.៣.២. ស្តីពីចំណុចវិវាទទី២៖** តើការទាមទាររបស់ដើមចោទឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងការប្រាក់មកឱ្យដើមចោទក្នុងអត្រាការប្រាក់ ១.៣៥ % ក្នុងមួយខែ លើប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ ជាការត្រឹមត្រូវដែរឬទេ?

**ខ.៣.៣. ស្តីពីចំណុចវិវាទទី៣៖** តើការទាមទាររបស់ដើមចោទឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងការប្រាក់ពិន័យមកដើមចោទគិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រា ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ ជាការត្រឹមត្រូវដែរឬទេ?

**ខ.៣.៤. ស្តីពីចំណុចវិវាទទី៤៖** តើការទាមទាររបស់ដើមចោទឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងថ្លៃសេវាកម្មច្បាប់ និងការខាតបង់ពេលវេលាមកដើមចោទចំនួន ១០.០០០.០០០ (ដប់លាន) រៀល ជាការត្រឹមត្រូវដែរឬទេ?

**ខ.៣.៥.ស្តីពីចំណុចវិវាទទី៥៖**តើការទាមទាររបស់ដើមចោទឱ្យអនុវត្តសាលក្រមនេះជាបណ្តោះអាសន្ន បានត្រង់ចំណុចទី ១ ទី២ និងទី៣ ជាការត្រឹមត្រូវដែរឬទេ?

**ខ.៤. ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ**

**ខ.៤.១. ស្តីពីចំណុចវិវាទទី១៖**

**ក. ការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖** ខ្ញុំស្នើសុំបង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក ដោយហេតុថាពីដើមសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ បានមកខ្ចីប្រាក់ដែលមានកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ ដែលបានព្រមព្រៀងប្រាក់ដើមចំនួន ១២២០០ (មួយម៉ឺនពីរពាន់ពីររយ) ដុល្លារអាមេរិក។ ដោយខាង



Scanned with CamScanner

សហចុងចម្លើយខកខានបង់ប្រាក់ដើម មកខាងគ្រឹះស្ថានគិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ដល់បច្ចុប្បន្ន។ កម្ចីប្រាក់នេះមានអ្នកជួយដាក់ប្រតិភោគឈ្មោះ ឈ្មោះ [redacted]លន ឈ្មោះ [redacted]គីន ឈ្មោះ [redacted]គី ឈ្មោះ[redacted]ផូ ដោយបានបង្កើតកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២។ កិច្ចសន្យាខ្ចីបរិភោគករណីភាគី ខ ប្រើប្រាស់ ឬខកខានក្នុងការ បំពេញកាតព្វកិច្ចតាមប្រការ ១ នោះភាគី ក មានសិទ្ធិប្រមូលបំណុលពីភាគី ខ មុនកាលកំណត់។ ហេតុនេះស្នើសុំទាមទារឱ្យសហចុងចម្លើយឈ្មោះ[redacted]សុខឡៃ ឈ្មោះ[redacted]ក័ក្រ ឈ្មោះ[redacted] លន ឈ្មោះ[redacted]គីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក។

**ខ. ការអះអាងរបស់សហចុងចម្លើយ៖** ពុំមាន ព្រោះអវត្តមាន។

**ខ.៤.២. ស្តីពីចំណុចវិវាទទី២៖**

**ក. ការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖** ខ្ញុំបាទស្នើសុំឱ្យសហចុងចម្លើយឈ្មោះ[redacted]សុខឡៃ ឈ្មោះ[redacted]ក័ក្រ ឈ្មោះ[redacted]លន ឈ្មោះ[redacted]គីន ឈ្មោះ [redacted]គី ឈ្មោះ[redacted]ផូ រួមគ្នាសងការប្រាក់មកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួនក្នុងអត្រាការប្រាក់ ១.៣៥ % ក្នុងមួយខែ លើប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ ដោយហេតុថា សហចុងចម្លើយបានព្រមព្រៀងបំពេញកាតព្វកិច្ចក្នុងការបង់អត្រាការប្រាក់ ១,៦ នៃកិច្ចសន្យា គឺបង់ចំនួន ១,៣៥ ភាគរយក្នុងមួយខែ ដោយសារតែជាប្រភេទឥណទានបង់ទាំងប្រាក់ដើម និងការប្រាក់ ហើយសហចុងចម្លើយខកខានបង់គិតចាប់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ហេតុនេះយោងតាមមាត្រា ៥៨៣ និងមាត្រា ៥៩១ នៃក្រម ចែងពីសិទ្ធិលើបំណុលលើប្រាក់ដើម និងការប្រាក់របស់អ្នកខ្ចីតាមកិច្ចសន្យាដែលបានព្រមព្រៀង។

**ខ. ការអះអាងរបស់សហចុងចម្លើយ៖** ពុំមាន ព្រោះអវត្តមាន។

**ខ.៤.៣. ស្តីពីចំណុចវិវាទទី៣៖**

**ក. ការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖** ខ្ញុំបាទស្នើសុំឱ្យសហចុងចម្លើយឈ្មោះ[redacted] សុខឡៃ ឈ្មោះ[redacted]ក័ក្រ ឈ្មោះ [redacted]លន ឈ្មោះ [redacted]គីន ឈ្មោះ [redacted]គី ឈ្មោះ ផន ផូ រួមគ្នាសងការប្រាក់ពិន័យមកដើមចោទគិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រា ២៤ (ម្ភៃបួន) ភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ ដោយហេតុថា សហចុងចម្លើយខកខានបង់ទាំងប្រាក់ដើម និងការប្រាក់ ហើយតាមកិច្ចសន្យាខ្ចីបរិភោគ ប្រការ ២ ចំណុច ២,៧ គូភាគីបានព្រមព្រៀងក្នុងអត្រា ២៤ (ម្ភៃបួន) ភាគរយ ក្នុងមួយឆ្នាំ ហេតុនេះស្របនឹងមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី ដែលជាបទប្បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់ និងមាត្រា ៤០៣ កថាខណ្ឌទី១ ការកំណត់ជាមុននូវចំនួននៃសំណង)។ ហេតុដូច្នេះដើមចោទមានសិទ្ធិទាមទារចាប់ពីថ្ងៃខកខាន ចំនួន ២៤ (ម្ភៃបួន) ភាគរយ គិតចាប់ពី ថ្ងៃទី១៥ ខែ



Scanned with CamScanner

កុម្ភៈ ឆ្នាំ២០២៣ លើប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក។

**ខ. ការអះអាងរបស់សហចុងចម្លើយ៖** ពុំមាន ព្រោះអវត្តមាន។

**ខ.៤.៤. ស្តីពីចំណុចវិវាទទី៤៖**

**ក. ការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖** ខ្ញុំស្នើសុំបង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted]សុខឡៃ ឈ្មោះ [redacted]ភ័ក្រ ឈ្មោះ [redacted]លន ឈ្មោះ [redacted]ភីន ឈ្មោះ [redacted]គី ឈ្មោះ [redacted] រួមគ្នាសងថ្លៃសេវាកម្មច្បាប់ និងការខាតបង់ពេលវេលាមកដើមចោទចំនួន ១០.០០០.០០០ (ដប់លាន) រៀល ដោយហេតុថា ព្រោះសហចុងចម្លើយមានកំហុសក្នុងការបំពេញកាតព្វកិច្ច តាមកិច្ចសន្យាខ្ចីបរិភោគនៃការចំណាយលើសេវាកម្មច្បាប់ ការខូចខាតពេលវេលា និងការចំណាយផ្សេងៗទៀត ផ្អែកកិច្ចសន្យាខ្ចីបរិភោគ ត្រង់ប្រការ ៣,១ រាល់សេចក្តីសម្រេច និងការដោះស្រាយវិវាទគឺជាបន្ទុករបស់ភាគីដែលបំពានកិច្ចសន្យា។

**ខ. ការអះអាងរបស់សហចុងចម្លើយ៖** ពុំមាន ព្រោះអវត្តមាន។

**ខ.៤.៥. ស្តីពីចំណុចវិវាទទី៥៖**

**ក. ការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖** ខ្ញុំបាទស្នើសុំឱ្យប្រាក់ប្រដាប់ក្តី និងការចំណាយ លើនីតិវិធីតុលាការជាបន្ទុករបស់សហចុងចម្លើយ ដោយហេតុថា ករណីបណ្តឹងនេះកើតចេញពីសហចុងចម្លើយ មិនបានបំពេញកាតព្វកិច្ច ផ្អែកតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី។

**ខ. ការអះអាងរបស់សហចុងចម្លើយ៖** ពុំមាន ព្រោះអវត្តមាន។

**ខ.៤.៦. ស្តីពីចំណុចវិវាទទី៦៖**

**ក.ការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖** ខ្ញុំស្នើសុំឱ្យអនុវត្តសាលក្រមនេះជាបណ្តោះអាសន្នបានត្រង់ចំណុចទី ១ ទី២ និងទី៣ នៃចំណុចទាមទារខាងលើ។

**ខ. ការអះអាងរបស់សហចុងចម្លើយ៖** ពុំមាន ព្រោះអវត្តមាន។

## សំអាងហេតុ

**ក. ការវិនិច្ឆ័យអំពីចំណុចវិវាទទី១៖**

**ក.១. ការទទួលស្គាល់អង្គហេតុ**

តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ កិច្ចសន្យាបង្កើតហ៊ីប៉ូតែកចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ រវាងដើមចោទ និងសហចុងចម្លើយ បង្ហាញថា សហចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទចំនួន ១២,២០០ (មួយម៉ឺនពីរពាន់ពីររយ) ដុល្លារអាមេរិក ពីដើមចោទ ហើយបានអនុវត្តកាតព្វកិច្ចដោយបង់ប្រាក់ដើម និងការប្រាក់។ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ សហចុងចម្លើយខកខានអនុវត្តកាតព្វកិច្ចរហូតដល់បច្ចុប្បន្ន សរុបប្រាក់នៅសល់ចំនួន ១១,៩៥០.៨១ (មួយម៉ឺន



Scanned with CamScanner

មួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក។ តុលាការទទួលស្គាល់ថា សហចុងចម្លើយជំពាក់ប្រាក់ចោទចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក។

**ក.២. ការវិនិច្ឆ័យ**

តុលាការបង្គាប់ឱ្យសហចុងចម្លើយរួមគ្នាដោយសាមគ្គីភាពសងប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក។

**ខ. ការវិនិច្ឆ័យអំពីចំណុចវិវាទទី២៖**

**ខ.១. ការទទួលស្គាល់អង្គហេតុ**

តាមកិច្ចសន្យាខាងលើ រយៈពេលខ្ចីប្រាក់គិតចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០៣០។ សហចុងចម្លើយខកខានសងប្រាក់គិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣។ អង្គហេតុដែលបង្កើតសិទ្ធិលើបំណុល កើតឡើងនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ហើយត្រូវអនុវត្តការសងជាបន្តបន្ទាប់តារាងកាលវិភាគសងប្រាក់។ ការប្រាក់ គឺជាចំនួនទឹកប្រាក់ដែលអាចគណនាបាន ហើយត្រូវគិតក្នុងអំឡុងពេលដែលកិច្ចសន្យាមានសុពលភាព។ ក្នុងរឿងក្តីនេះ ដើមចោទបានដាក់ពាក្យបណ្តឹងទាមទារប្រាក់មកសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ ស្របទៅនឹងកិច្ចសន្យារវាងដើមចោទ និងសហចុងចម្លើយ ដែលនាំឱ្យកិច្ចសន្យារវាងដើមចោទ និងសហចុងចម្លើយ ត្រូវរំលាយនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣។ ហេតុនេះ ដើមចោទមិនអាចទាមទារឱ្យសហចុងចម្លើយសងការប្រាក់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០៣០ បានឡើយ។

**ខ.២. ការវិនិច្ឆ័យ**

តុលាការបង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី រួមគ្នាដោយសាមគ្គីភាពសងការប្រាក់ចំនួន ១.៣៥ (មួយក្បៀសប្រាំ) ភាគរយ ក្នុងមួយខែ លើប្រាក់ចំនួន ១១, ៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣។

**គ.ការវិនិច្ឆ័យអំពីចំណុចវិវាទទី៣៖**

**គ.១. ការទទួលស្គាល់អង្គហេតុ**

ដើមចោទបានទាមទារឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងការប្រាក់ពិន័យមកដើមចោទគិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងគ្រប់ក្នុងអត្រា ២៤ (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក។ តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ ត្រង់ប្រការ ២ ចំណុច ២.៧ រវាងដើមចោទ និងសហចុងចម្លើយ បានព្រមព្រៀងកំណត់ប្រាក់ពិន័យចំនួន ២៤ (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុច



Scanned with CamScanner

ប៉ែតសិប) ដុល្លារអាមេរិក។ ការប្រាក់ពិន័យខាងលើនេះ តាមក្រមរដ្ឋប្បវេណី គឺជាការប្រាក់នៃការយឺតយ៉ាវ តាមមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី ហេតុនេះ តុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ។

**គ.២. ការវិនិច្ឆ័យ**

តុលាការបង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] ភីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាសងការប្រាក់នៃការយឺតយ៉ាវក្នុងអត្រា ២៤ (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់។

**ឃ.ការវិនិច្ឆ័យអំពីចំណុចវិវាទទី៤៖**

**ឃ.១. ការទទួលស្គាល់អង្គហេតុ**

ដើមចោទទាមទារឱ្យសហចុងចម្លើយរួមគ្នាសងសេវាកម្មច្បាប់ និងការខាតបង់ពេលវេលាចំនួន ១០.០០០.០០០ (ដប់លាន) រៀល។

**ឃ.២. ការវិនិច្ឆ័យ**

ការទាមទារសោហ៊ុយសេវាកម្មច្បាប់របស់ដើមចោទ តុលាការយល់ឃើញថា សោហ៊ុយសេវាកម្មច្បាប់ដែលកើតមាន គឺជាចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្តកាតព្វកិច្ច តាមមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី ហេតុនេះ តុលាការនឹងសម្រេចក្នុងភាពសមរម្យ ដោយបង្គាប់ឱ្យសហចុងចម្លើយបង់ចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្តកាតព្វកិច្ចចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

**ង. អំពីការប្រកាសឱ្យអនុវត្តបណ្ដោះអាសន្ន**

ក្នុងរឿងក្ដីនេះ ដើមចោទបានទាមទារឱ្យតុលាការធ្វើការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ឃើញថា ដើមចោទមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិទាមទារ ហើយពុំមានភស្តុតាងណាមួយដែលមាន និងដែលអាចធ្វើឱ្យមាននត្ថិភាពនៃសិទ្ធិទាមទាររបស់ដើមចោទនោះទេ តុលាការនឹងសម្រេចប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នលើចំណុច ក នៃការទាមទាររបស់ដើមចោទ។

**ច. អំពីបន្ទុកនៃការប្រាក់ប្រដាប់ក្ដី**

**យល់ឃើញថា** តាមមាត្រា ៦៤ មាត្រា ១៨២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការនឹងសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្ដី នៅសាលាដំបូងឱ្យជាបន្ទុករបស់សហចុងចម្លើយ។

**សេចក្ដីសម្រេចបញ្ចប់**

ក. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] **សុខឡៃ** ឈ្មោះ [redacted] **ភ័ក្រ** ឈ្មោះ [redacted] **លន** ឈ្មោះ [redacted] **ភីន** ឈ្មោះ [redacted] **គី** ឈ្មោះ [redacted] **ផូ** រួមគ្នាដោយសាមគ្គីភាពសងប្រាក់ចំនួន **១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែត សិប) ដុល្លារអាមេរិក** ឱ្យមកដើមចោទដែលជា [redacted] **(ខេមបូឌា) ម.ក** តំណាងដោយឈ្មោះ [redacted] GON។

ខ. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] **សុខឡៃ** ឈ្មោះ [redacted] **ភ័ក្រ** ឈ្មោះ **វ៉ន លន** ឈ្មោះ [redacted] **ភីន** ឈ្មោះ [redacted] **គី** ឈ្មោះ [redacted] **ផូ** រួមគ្នាដោយសាមគ្គីភាពសងការប្រាក់ក្នុងអត្រាការប្រាក់ **១.៣៥ (មួយក្បៀសសាមសិប**



Scanned with CamScanner

ប្រាំ) ភាគរយ ក្នុងមួយខែ លើប្រាក់ចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣។

គ. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] គីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាដោយសាមគ្គីភាពសងការប្រាក់នៃការយឺតយ៉ាវក្នុងអត្រា ២៤ (ម្ភៃបួន) ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ចំនួន ១១,៩៥០.៨១ (មួយម៉ឺនមួយពាន់ប្រាំបួនរយហាសិបចុចប៉ែតសិប) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងគ្រប់។

ឃ. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុខឡៃ ឈ្មោះ [redacted] ភ័ក្រ ឈ្មោះ [redacted] លន ឈ្មោះ [redacted] គីន ឈ្មោះ [redacted] គី ឈ្មោះ [redacted] ផូ រួមគ្នាដោយសាមគ្គីភាពសងចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្តកាតព្វកិច្ចចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

ង. ប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុច ក នៃសេចក្ដីសម្រេចខាងលើនេះ។

ច. ប្រាក់ប្រដាប់ក្ដីនៅជាន់សាលាដំបូង ជាបន្ទុករបស់សហចុងចម្លើយ។

ថ្ងៃ ពុធ ២ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្ដាល,ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ២ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្ដាល, ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner